## ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សារលិខិតរំលែកទុក្ខ

## ជូនចំពោះ
## ក្រុមគ្រួសារនៃសព ព្រឹន្ទបាលឯក សួន រ៉ាន

*លោក និងលោកស្រី ក្រុមគ្រួសារនៃសព ជាទីស្រឡាញ់រាប់អាន!*

ខ្ញុំ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពិតជាមានក្តីក្តុកក្តួលរន្ធត់ចិត្តឥតឧបមាដោយបានទទួលដំណឹងថា **ព្រឹន្ទបាលឯក សួន រ៉ាន** បានទទួលមរណភាពក្នុងជន្មាយុ ៤៧ឆ្នាំ ដោយហេតុការណ៍ប៉ះទង្គិចគ្នារវាងកងទ័ពកម្ពុជា-ថៃ នៅព្រំដែនតំបន់មុំបី ស្ថិតក្នុងខេត្តព្រះវិហារ កាលពីព្រឹកថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥។

ក្នុងឱកាសប្រកបដោយក្តីខ្សឹកខ្សួលរំជួលចិត្តដ៏មហាក្រៀមក្រំនេះ យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសមានទុក្ខ និងសេចក្តីសោកស្តាយស្រណោះអាឡោះអាល័យជាទីបំផុតចំពោះ **ក្រុមគ្រួសាររបស់ព្រឹន្ទបាលឯក សួន រ៉ាន** ដែលនេះជាការបាត់បង់នូវកូនប្រុស បងប្រុស ប្អូនប្រុសជាទីស្រឡាញ់ ប្រកបដោយព្រហ្មវិហារធម៌ចំពោះក្រុមគ្រួសារ ហើយក៏ជាការបាត់បង់នូវយោធិនស្នេហាជាតិដ៏អង់អាចក្លាហាន ដែលបានធ្វើពលិកម្មប្រកបដោយឆន្ទៈមនសិការមោះមុត និងបានលះបង់អស់ពីកម្លាំងកាយចិត្តបញ្ញាស្មារតី ដើម្បីបុព្វហេតុ **ជាតិ សាសនា ព្រះមហាក្សត្រ** ជាពិសេស បានរួមចំណែកយ៉ាងសកម្មក្នុងកិច្ចការពារអធិបតេយ្យភាព បូរណភាពដែនដី ដើម្បីជានាថៃរក្សាសុខសន្តិភាពរហូតដល់ថ្ងៃអវសាននៃជីវិត។

សូម **លោក និងលោកស្រី ក្រុមគ្រួសារនៃសព** ទទួលនូវការចូលរួមរំលែកទុក្ខដ៏ក្រៀមក្រំនេះ និងការស្រឡាញ់រាប់អានយ៉ាងជ្រាលជ្រៅពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃព្រហស្បតិ៍ ៣កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៥

**រដ្ឋមន្ត្រី**

**ហេង សួរ**

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩*